រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៩៣

# សេចក្តីសំរេចលេខ ៣៩ សសរ

# ស្តីពីការបង្កើតគណៈកម្មការជួសជុលនិងកែលំអ សាលមហោស្រពទន្លេបាសាក់និងសាលមហោស្រពចេនឡា

# រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះចៅក្រុង កម្ពុជាធិបតីចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- ផ្អែកតាមសំណូមពរចាំបាច់

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការមួយដើម្បីជួសជុល និងកែលំអសាលមហោស្រពទន្លេបាសាក់ និងសាលមហោស្រពចេនឡាដែលមានសមាសភាពដូចតទៅ ÷

១.ឯកឧត្តម អ៊ឹង ហ៊ួត ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ជាប្រធាន

២. ឯកឧត្តម ម៉ម សូផាណា ទីប្រឹក្សាឯកឧត្តម នាយករដ្ឋមន្ត្រី ជាអនុប្រធាន

៣. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

៤. តំណាងសាលាក្រុងភ្នំពេញ ជាសមាជិក

៥. តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាលេខាធិការ

**ប្រការ ២ :** គណៈកម្មការនេះ មានភារកិច្ចដូចតទៅ ÷

- សិក្សាលើគំរោងជួសជុល និងកែលំអ សាលមហោស្រពទន្លេបាសាក់ និងសាលមហោស្រពចេនឡា អោយបានសមរម្យតាមស្ថានភាពប្រទេសជាតិ និងខ្នាតអន្តរជាតិដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសំរេច ។

ជួសជុលនិងកែលំអ សាលមហោស្រពទន្លេបាសាក់ និងសាលមហោស្រពចេនឡា ក្រោយពីរាជរដ្ឋាភិបាលបានសំរេចលើគំរោងដែលបានស្នើឡើង ។

**ប្រការ ៣ :** គណៈកម្មការនេះមានសិទ្ធិអញ្ជើញតំណាងក្រសួងស្ថាប័នពាក់ព័ន្ធមកប្រជុំ និងចូលរួមក្នុងការពិនិត្យដោះស្រាយការងារខាងលើនេះ ។

**ប្រការ ៤ :** គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីសំរួលការងារ ។

**ប្រការ ៥ :** សហរដ្ឋមន្ត្រីទទួលបន្ទុកស្តីពីការរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រតិភូនៃរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ និងឯកឧត្តម អស់លោក ដែលមាននាមក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់បំផុត ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា និង ត្រា
**នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និង ត្រា
**ហ៊ុន សែន**

******